ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្តបាត់ដំបង
សំណុំរឿងព្រហ្មទណ្ឌ
លេខ : ៥២៥ ចុះថ្ងៃទី ០១
ខែ សីហា ឆ្នាំ ២០០៥
សាលក្រមព្រហ្មទណ្ឌ
លេខ : ០៧ "ក" ចុះថ្ងៃទី ០៦
ខែ មករា ឆ្នាំ ២០០៦

**នាមនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តបាត់ដំបង**

បានបើកសវនាការជាសាធារណៈនៅនាទីតុលាការខេត្តបាត់ដំបង នៅថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ជាប្រធានតុលាការខេត្តបាត់ដំបង

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្តបាត់ដំបង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**ដើម្បីជំនុំជំរះ**

រឿងក្តីព្រហ្មទណ្ឌលេខ ៥២៥ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៥ ដែលមានជនជាប់ចោទ ។

១-ឈ្មោះ **រ ទ** ហៅ **ឆារ** ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានរបររកស៊ី ហៅម៉ូយឡាន មានទីកន្លែងកំណើតនៅភូមិ ី ឃុំព្រះពន្លា ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ មានកំរិតវប្បធម៌ថ្នាក់ទី ០២ថ្មី កាន់សាសនា មានទីលំនៅសព្វថ្ងៃនៅភូមិចំការសំរោង ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង មានប្រពន្ធឈ្មោះ **ស យ** (រ) មានកូន ០២នាក់ មានឪពុកឈ្មោះ **ស ដ** (ស) មានម្តាយឈ្មោះ **ន ឡ** (រ) ទោសពីមុនគ្មាន ។ ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥ នៅចំណុចភូមិអង្គ ឃុំអូរចារស្រុកបាត់ដំបង ខេត្តបាត់ដំបង ហើយត្រូវបានឃុំខ្លួន តាមដីកាលេខ : ២៦២ ដ.ឃ.ខ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៥ នៅអាគារឃុំខ្លួននៃពន្ធនាគារខេត្តបាត់ដំបង ។

ត្រូវចោទពីបទ : ចោរកម្ម តាមបញ្ញត្តិមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ប្រព្រឹត្តនៅភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥ ។

២-ឈ្មោះ **ភ សណ** ភេទស្រី អាយុ៤៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិអូរស្រឡៅ ឃុំអូរដំបង ស្រុកបាត់ដំបង ខេត្តបាត់ដំបង សាសនាព្រះពុទ្ធ ទីលំនៅភូមិកកោះ ឃុំអូរតាគី ស្រុកបាត់ដំបង ខេត្តបាត់ដំបង របររកស៊ីទិញអេតចាយ កំរិតវប្បធម៌ថ្នាក់ទី ០៧ ចាស់ ឪពុកឈ្មោះ **ម ត** (ស) ម្តាយឈ្មោះ **ខ ឈ** (ស) ប្តីឈ្មោះ **រ សប** មានកូន ០៦នាក់ ទោសពីមុនគ្មាន ។ (ក្រៅឃុំ) ។



Scanned with CamScanner

ត្រូវចោទពីបទ ទទួលផលនៃអំពើចោរកម្ម តាមបញ្ញត្តិមាត្រា ៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។ ប្រព្រឹត្តនៅភូមិកកោះ ឃុំអូរតាគី ស្រុកថ្មគោល ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥ ។

**ជនរងគ្រោះ :**

១-ឈ្មោះ ច ឃ ភេទប្រុស អាយុ ៤០ឆ្នាំ ជាតិខ្មែរ របររកស៊ីបុគ្គលិកក្រុមហ៊ុនផ្សារបឹងឈូក ទីលំនៅភូមិព្រៃកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

## ការប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ :

នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥ វេលាម៉ោង ១៩ ឈ្មោះ អ ខ បានដើរទៅបេនឡានផ្សារបឹងឈូក បានឃើញរឺឡឺកិនថ្នល់គេចតក្នុងឃ្លាំង ហើយក៏ចូលទៅបើកទ្វាររូឡូនោះលួចយកអាគុយកម្លាំង ១០០អំពែរ ០១គ្រឿង យកទៅលក់ឱ្យឈ្មោះ គ សណ នៅអូរតាគីបានតម្លៃ ២៨.០០០រៀល រួចក៏យកលុយនោះដើរចាយវាយក៏ត្រូវសមត្ថកិច្ចចាប់តែម្តង ។

-តាមរបាយការណ៍លេខ ០៩២ សស.ព្រទ ចុះថ្ងៃ ៣១ ខែ កក្កដា ឆ្នាំ ២០០៥ របស់កងរាជអាវុធហត្ថស្រុកបាត់ដំបង បានបញ្ជាក់ថា នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥ វេលាម៉ោង ១៩ នៅត្រង់ចំណុចបេនឡានផ្សារបឹងឈូកមានករណីចោរកម្ម ០១កើតឡើងបង្កដោយជនល្មើសឈ្មោះ អ ខ បានលួចយកអាគុយ ១០០អំពែរ ពីរូឡូកិនថ្នល់ដែលមានឈ្មោះ ច ឃ ជាអ្នកមើលខុសត្រូវ ហើយបានយកអាគុយនោះទៅលក់នៅភូមិកកោះ ឃុំអូរតាគីក្នុងតំលៃ ២៦.០០០រៀល ហើយក៏ជិះម៉ូតូឌុបត្រឡប់មកវិញ ក៏ត្រូវសមត្ថកិច្ចអាវុធហត្ថឃាត់ខ្លួនតែម្តង ។

## នៅចំពោះមុខនាពេលសទនាការ

-ឈ្មោះ អ ខ ជាជនជាប់ចោទបានឆ្លើយថា : ខ្លួនពិតជាបានលួចយកអាគុយពីក្នុងរូឡូរបស់គេពិតប្រាកដមែន ។ មូលហេតុលួចមកពីអត់លុយចាយ ។

-ឈ្មោះ គ សណ ជាជនជាប់ចោទបានឆ្លើយថា : ខ្លួនពិតជាបានទិញអាគុយ ០១គ្រឿង កម្លាំង ១០០អំពែរ ពីឈ្មោះ ខ ពិតមែនក្នុងតម្លៃ ២៦.០០០រៀល ។

-តាមការអានចម្លើយឈ្មោះ ច ឃ បានឆ្លើយថា (មើលឯកសារលេខ ១៦) ។

## តំណាងអយ្យការបានធ្វើសន្និដ្ឋានថា :

មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ អ ខ និង ឈ្មោះ គ សណ ពីបទចោរកម្ម និង ទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិព្រៃកមហាទេព ឃុំស្វាយប៉ោ និង ភូមិកកោះ ឃុំអូរតាគី កាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥ ។ ស្នើសុំតម្កល់បទចោទទុកជាបានការពេញទាំងមូល និង សុំឱ្យតុលាការផ្តន្ទាទោសលើអ្នកទាំងពីរដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗពី ១២ខែ ដល់ ៣០ខែ ពីបទចោទ ។

-បានស្តាប់ចម្លើយដោះសាររបស់ជនជាប់ចោទ

-បានស្តាប់ចម្លើយឱ្យការណ៍របស់ជនរងគ្រោះ ចម្លើយឱ្យការណ៍របស់សាក្សី

-បានស្តាប់ការសួរដេញដោល ចោទឆ្លើយតទល់

-បានពិនិត្យកំណត់ហេតុ ឯកសារ ភស្តុតាងនានា



Scanned with CamScanner

-បានស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់ទោសរបស់តំណាងអយ្យការ

-បានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-បានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការខេត្តបាត់ដំបងយល់ឃើញថា

-ពិតជាកើតមាននូវអំពើចោរកម្មនៅភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥ ប្រាកដមែន ។

-អំពើចោរកម្មដែលកើតមាននៅទីកន្លែង និង ពេលវេលាដូចខាងលើ ពិតជាប្រព្រឹត្តឡើងដោយឈ្មោះ អ ខ បានលបលួចយកអាគុយជារបស់ឈ្មោះ ច ឆ ដែលទុកនៅលើរូឡូក្នុងឃ្លាំងរបស់ខ្លួននៅផ្សារបឹងឈូកពិតប្រាកដមែន ។

-អំពើដែលឈ្មោះ អ ខ បានប្រព្រឹត្តនៅទីកន្លែង និង ពេលដូចខាងលើនេះមានធាតុផ្សំគ្រប់គ្រាន់ ជាបទចោរកម្មដូចមានបញ្ញត្តិក្នុងមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ឈ្មោះ អ ខ ជាសមត្ថជនគាត់មានអាយុ ២២ឆ្នាំ មានស្មារតីជានាល្អ គាត់បានប្រព្រឹត្តអំពើដោយចេតនាលបលួចរឹបយកអាគុយជាទ្រព្យរបស់ឈ្មោះ ច ឆ ដែលទុកនៅលើរូឡូក្នុងឃ្លាំងរបស់ខ្លួនយកទៅចាត់ចែង លក់ឱ្យទៅឈ្មោះ ត សណ ក្នុងតម្លៃ ២៨.០០០រៀល យកប្រាក់ចាយវាយបំរើផលប្រយោជន៍ សួនតួបុគ្គលផ្ទាល់ខ្លួនបានសំរេច ។

-ពិតជាកើតមាននូវអំពើទទួលផល នៃអំពើចោរកម្មនៅភូមិកកោះ ឃុំអូរតាគី ស្រុកថ្មគោល កាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥ ប្រាកដមែន ។

-អំពើទទួលផល នៃអំពើរចោរកម្មដែលកើតមាននៅទីកន្លែង និង ពេលវេលាដូចខាងលើនេះពិតជាប្រព្រឹត្តឡើងដោយឈ្មោះ ត សណ បានទទួលទិញអាគុយមួយគ្រឿងពីឈ្មោះ អ ខ ក្នុងតម្លៃទាបបំផុត ២៨.០០០រៀល ការទិញប្រព្រឹត្តទៅនៅវេលាយប់ ។

-អំពើដែលឈ្មោះ ត សណ បានប្រព្រឹត្តនៅទីកន្លែង និង ពេលវេលាដូចខាងលើនេះមានធាតុផ្សំគ្រប់គ្រាន់ជាបទទទួលផល នៃអំពើចោរកម្ម ដូចមានបញ្ញត្តិក្នុងមាត្រា ៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។ ឈ្មោះ ត សណ ជាសមត្ថជនគាត់មានអាយុ ៤៨ឆ្នាំ មានស្មារតីជានាល្អ គាត់បានលូកដៃប្រព្រឹត្តបទល្មើសដោយចេតនាទទួលទិញអាគុយមួយគ្រឿងពីឈ្មោះ អ ខ ក្នុងតម្លៃ ២៨.០០០រៀល ជាតម្លៃទាបបំផុតពីឈ្មោះ អ ខ ដែលបានមកពីអំពើចោរកម្ម ការទិញនៅវេលាយប់ និង ពុំមានកិច្ចសន្យាលក់ទិញវត្ថុត្រឹមត្រូវ ។

## យល់ឃើញថា

មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ អ ខ ពីបទចោរកម្ម និង ឈ្មោះ ត សណ ពីបទទទួលផល នៃអំពើចោរកម្មប្រព្រឹត្តនៅទីកន្លែង និង ពេលវេលាដូចការចោទប្រកាន់របស់អយ្យការប្រាកដមែន ។

**ភស្តុតាងដាក់បន្ទុកមាន :**

-ចម្លើយដោះសាររបស់ជនជាប់ចោទឈ្មោះ អ ខ និង ឈ្មោះ ត សណ បានឆ្លើយបញ្ជាក់យ៉ាងច្បាស់អំពីអំពើដែលខ្លួនបានប្រព្រឹត្តហើយវាស៊ីសង្វាក់គ្នាទៅនឹងចម្លើយឱ្យការរបស់ជនរងគ្រោះ, សាក្សី វត្ថុ

តាងដែលរឹបអូសបាន និង កាលៈទេសៈ នៃបទល្មើស ។

-ចម្លើយឱ្យការណ៍របស់ជនរងគ្រោះឈ្មោះ ច ហ និង ចម្លើយឱ្យការណ៍របស់សាក្សីឈ្មោះ ឆ ល បាន បង្ហាញយ៉ាងច្បាស់លាស់ពីអំពើរបស់ជនជាប់ចោទ ហើយវាស៊ីសង្វាក់គ្នាទៅនឹងចម្លើយដោះសាររបស់ ជនជាប់ចោទទាំងពីរនាក់ ។

-កំណត់ហេតុឯកសារភស្តុតាងនានាធ្វើឡើងដោយនគរបាលយុត្តិធម៌ ។

## យល់ឃើញថា

ឈ្មោះ អ ទ ជាមនុស្សមិនដែលមានទោសពីមុនមក គាត់មានកិរិតវប្បធម៌ទាប គាត់មានជីវភាពក្រខ្សត់ ជាកត្តាជំរុញឱ្យគាត់លូកដៃប្រព្រឹត្តបទល្មើស វត្ថុដែលជាមុខសញ្ញាបទល្មើសបានរំលោភបំពានមានតម្លៃទាប ជាហេតុ អាចឱ្យតុលាការយកមកពិចារណាជាស្ថានសម្រាលទោសឱ្យគាត់បាន ។

ឈ្មោះ ត **សណ** ជាជនមិនដែលមានទោសពីមុនមក គាត់បានប្រព្រឹត្តបទល្មើសមជ្ឈិម វត្ថុដែលគាត់បាន ទទួលផល នៃអំពើរចោរកម្មមានតម្លៃទាប គាត់មានលំនៅដ្ឋាន គ្រួសារ មុខរបរត្រឹមត្រូវ ជាហេតុតុលាការអាច យកមកពិចារណាជាស្ថានសំរាលទោសក្នុងការសំរេចពីទណ្ឌកម្ម និង ព្យួរទោសបាន ។

## ហេតុដូច្នេះតុលាការវិនិច្ឆ័យសេចក្តី

១-ក-ផ្តន្ទាទោស : ឈ្មោះ អ ទ ដាក់ពន្ធនាគារកំណត់ ០៩ខែគត់ ដោយគិតចាប់ពីថ្ងៃឃុំខ្លួន ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៥ ។ ពីបទ **ចោរកម្ម** ប្រព្រឹត្តនៅភូមិព្រៃកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥ ។

ខ-ផ្តន្ទាទោសឈ្មោះ **ត សណ** ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ តែទោសនេះ ឱ្យឈ្មោះ **ត សណ** ទទួល ទោសព្យួរ ដោយកំណត់រយៈពេលសាកល្បង ០៥ឆ្នាំ គិតចាប់ពីក្រោយពេលប្រកាសសាលក្រម នេះតទៅ ។ ពីបទទទួលផលនៃអំពើចោរកម្ម ប្រព្រឹត្តនៅភូមិកកោះ ឃុំអូរតាគី ស្រុកថ្មគោល ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥ ។

បទល្មើសព្រហ្មទណ្ឌ ទណ្ឌកម្ម និង ការផ្តន្ទាទោសមានបញ្ញត្តិក្នុងមាត្រា ៤៣ និង មាត្រា ៥១ នៃច្បាប់ ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។ តាមបទបញ្ញត្តិមាត្រា ៨ ច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ ។

២-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ **អ ទ** ហៅ **ធារ** និង **ត សណ** ។ បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ចៅក្រមជំនុំជំរះ**

[redacted]

---

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកអ្នកអនុវត្តសាលក្រម ឱ្យបានសំរេចតាម សាលក្រមនេះ និង ឱ្យអាជ្ញាធរគ្រប់តំណែង គ្រប់ជាន់ថ្នាក់ជួយអនុវត្ត បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។



Scanned with CamScanner

បានឃើញ

បាត់ដំបង.ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៦

ប្រធានតុលាការខេត្ត

[redacted]

បាត់ដំបង.ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៦

ជ.ក្រឡាបញ្ជីសវនាការ

[redacted]

Scanned with CamScanner